ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ០៧៣៧ព.ណ.កសស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ភ្នំពេញ, ថ្ងៃទី១២ ខែមិនា ឆ្នាំ ២០១៥

## ជម្រាបមក

## លោកនាយកក្រុមហ៊ុន ឆាយ ហាក់លី អ៊ីមផត អិចផត ខូអិលធីឌី

**កម្មវត្ថុ:** លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកគ្រឿងអគ្គិសនីម៉ាក ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**យោង:** - ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

- លិខិតរបស់ក្រុមហ៊ុន **ឆាយ ហាក់លី អ៊ីមផត អិចផត ខូអិលធីឌី** ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៣៥៣៦៣/១១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១០ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងពាណិជ្ជកម្មសូមបញ្ជាក់ជូនលោកនាយកជ្រាបថា តាមរយៈការចុះបញ្ជីម៉ាក ដែលមានលេខចុះបញ្ជី KH/៣៥៣៦៣/១១ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនរបស់លោកបានទទួលសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនេះ ក្នុងការផលិត នាំចូល ចែកចាយ ដាក់តាំង ឬផ្សព្វផ្សាយចំពោះទំនិញដែលជាកម្មវត្ថុនៃការចុះបញ្ជី នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាស្វ័យប្រវត្តិ ដូចមានចែងក្នុងមាត្រា ៣ និងមាត្រា ១១ នៃច្បាប់ដែលបានយោងខាងលើនេះ ។ សិទ្ធិផ្តាច់មុខនេះ នឹងត្រូវបាត់បង់ទៅវិញក្នុងករណីដែលការចុះបញ្ជីម៉ាក ត្រូវបានបាត់បង់សុពលភាពដោយប្រការណាមួយនោះ ។

នីតិបុគ្គលដែលទទួលបានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក នេះ ត្រូវបោះពុម្ពផ្សាយលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខនេះ ក្នុងទំព័រខាងមុខរបស់សារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានច្បាប់ និងសារាចរណែនាំរបស់រាជរដ្ឋាភិបាលទាក់ទងនឹងការគ្រប់គ្រងសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក។

អាស្រ័យហេតុនេះ សូមលោកនាយកក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋលេខាធិការ

អ៊ុក ប្រជា

<u>ចម្លងជូន:</u>
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់**
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- ឯកសារ - កាលប្បវត្តិ